ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ អង្គារ ៨ កើត ខែ អាសាឍ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៩*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មាន
## ស្តីពីជំនួបរវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនឹងលោកស្រី Yong Sarah Zhou ប្រធានស្ថានតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)

នាព្រឹកថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសមជាមួយលោកស្រី Yong Sarah Zhou ប្រធានស្ថានតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំកម្ពុជា ក្នុងខណៈដែលលោកស្រីបានបញ្ចប់អាណត្តិបេសកកម្មរបស់លោកស្រីនៅកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់**លោកស្រី** Yong Sarah Zhou និងវាយតម្លៃខ្ពស់ចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលជានិច្ចកាលតែងតែរួមចំណែកក្នុងកិច្ចការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា តាមរយៈកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និតរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងមូលនិធិរូបិយវត្ថុអន្តរជាតិ ។ បន្ថែមលើកិច្ចសហប្រតិបត្តិការជិតស្និទ្ធ, រូបលោកស្រីផ្ទាល់ ក៏ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំកម្ពុជា បានចូលរួមចំណែកយ៉ាងសកម្មក្នុងការកសាងសមត្ថភាពមន្ត្រីជំនាញកម្ពុជា តាមរយៈការបណ្តុះបណ្តាល, ការចែករំលែកបទពិសោធន៍ជាក់ស្តែង និងការអភិវឌ្ឍជំនាញដល់មន្ត្រីកម្ពុជា ក៏ដូចជា ការជ្រើសរើសមន្ត្រីសេដ្ឋវិទូកម្ពុជា ជាអ្នកហាត់ការ (Secondee) ប្រចាំនៅការិយាល័យមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំកម្ពុជា ។ ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានស្នើលោកស្រីជួយផ្សព្វផ្សាយពីស្ថានភាពអភិវឌ្ឍ ការរីកចម្រើនជាក់ស្តែង និងការពិតនៅកម្ពុជានាពេលបច្ចុប្បន្ន ជូនដល់ថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីនៅទីស្នាក់ការកណ្តាលនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ក៏ដូចជាតាមវេទិកានានាដែលលោកស្រីអាចនឹងអញ្ជើញចូលរួម ។

**លោកស្រី** Yong Sarah Zhou ប្រធានស្ថានតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំកម្ពុជា បានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានកោតសរសើរ និងអបអរសាទរចំពោះសមិទ្ធផលដែលកម្ពុជា សម្រេចបានកន្លងមកដែលលោកស្រីជាសាក្សីផ្ទាល់ ព្រមទាំង បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាង IMF ជាមួយរដ្ឋាភិបាលកម្ពុជា ។ **លោកស្រី Yong Sarah Zhou** បានបញ្ជាក់ថា លោកស្រីមានការពេញចិត្តយ៉ាងខ្លាំង ចំពោះបេសកកម្មនៅកម្ពុជាក្នុងរយៈពេលប្រមាណ ៤ ឆ្នាំនេះ ដែលជាឱកាសដ៏ពិសេសក្នុងការអង្កេតឃើញផ្ទាល់នូវវឌ្ឍនភាព, ការអភិវឌ្ឍយ៉ាងឆាប់រហ័ស និងកំណើនសេដ្ឋកិច្ចដ៏រឹងមាំរបស់កម្ពុជា ។ លោកស្រី សន្យានឹងជួយផ្សព្វផ្សាយពីស្ថានភាពអភិវឌ្ឍ ការរីកចម្រើនពិតជាក់ស្តែងនៅកម្ពុជា នៅតាមវេទិកានានាដែលលោកស្រីនឹងចូលរួម ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** សង្ឃឹមយ៉ាងមុតមាំស្មារតីនៃកិច្ចសហប្រតិបត្តិការល្អ និងជិតស្និទ្ធនៅតែបន្តជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ ក៏ដូចជា ជាមួយប្រធានស្ថានតំណាងថ្មីដែលអញ្ជើញមកបន្តបេសកកម្មបន្ទាប់ពីលោកស្រីនាពេលខាងមុខ ហើយបានជូនពរ**លោកស្រី** Yong Sarah Zhou ឱ្យទទួលបានជោគជ័យក្នុងបំពេញភារកិច្ចថ្មី ។